# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញ ឬសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម គឺជាអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា ដែលមានស្រាប់ ពោលគឺសាលាដំបូង និងតុលាការកំពូល ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែល ទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាបានទទួលស្គាល់ ហើយបានប្រព្រឹត្តក្នុងអំឡុងពេលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។



ភូមិអង្គ ឃុំកន្ទោក ស្រុកអង្គស្នួល តាមផ្លូវជាតិលេខ ៤

# ជនរងគ្រោះ

**ក-នរណាជាជនរងគ្រោះ?** : មានន័យថា ជនទាំងឡាយដែលបានទទួលរងគ្រោះដោយការធ្វើទុក្ខទោស ឬការប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ដូចមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

ជនរងគ្រោះគឺជាជនដែលទទួលរងការបាត់បង់ជីវិត ការឈឺចាប់ខាងផ្លូវកាយ ឬ ផ្លូវចិត្ត (ឧ. ក្លាយជាមនុស្សមានស្មារតីមិនហ្នឹងហ្ន ឬ បាត់បង់ឪពុក ម្តាយ កូន ) ការបាត់ទ្រព្យសម្បត្តិ ឬ ខាងផ្នែកសេដ្ឋកិច្ច (ជាលក្ខណៈបុគ្គលក្តី ជាលក្ខណៈសមូហភាពក្តី ) ពីអំពើអាក្រក់ ឬ អំពើល្មើស។

ចាត់ទុកជាជនរងគ្រោះផងដែរ នូវសាច់ញាតិជិតស្និទ្ធ ឬ អ្នកនៅក្នុងបន្ទុកនៃជនរងគ្រោះ ដោយផ្ទាល់ ( ឧ. ឪពុក ម្តាយ ឬកូន )។

## ខ- តួនាទីរបស់ជនរងគ្រោះ

ជនរងគ្រោះដើរតួនាទីយ៉ាងសំខាន់នៅក្នុងបទល្មើសព្រហ្មទណ្ឌ។ នៅក្នុងតុលាការកម្ពុជា ជនរងគ្រោះតែងតែជាគូភាគីនៃរឿងក្តីពីព្រោះគេគឺជាដើមបណ្តឹងរដ្ឋប្បវេណី។ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន បានផ្តល់សិទ្ធិដល់ជនរងគ្រោះក្នុងការតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណី ( មាត្រា ១៦ និង ១៣១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ ១៩៩៣ )។ មានន័យថា ជនរងគ្រោះមិនមែនជាសាក្សីនៃរឿងក្តីរបស់ខ្លួននោះទេ តែជាគូភាគី។ ការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើទៅបានដំរាបណាចៅក្រមមិនទាន់ចេញសាលក្រម ( មាត្រា ១៣១ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ១៩៩៣ ) ។

ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះមានសារៈសំខាន់ណាស់ ព្រោះតាមរយៈវិធីនេះ ជនរងគ្រោះមិនត្រឹមតែអាចស្នើសុំសំណងជំងឺចិត្តប៉ុណ្ណោះទេ តែនៅមានសិទ្ធិផ្សេងទៀត ដែលប្រហាក់ប្រហែលទៅនឹងសិទ្ធិរបស់ជនជាប់ចោទដែរ ដូចជា សិទ្ធិសុំអោយមានការចាត់វិធានការស៊ើបអង្កេតណាមួយ ការធ្វើកោសល្យវិច័យ សិទ្ធិមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជី ឬ សិទ្ធិទទួលបានព័ត៌មានជាដើម។ សិទ ្ធិទាំងនេះ សាក្សីពុំមានឡើយ។

## គ- សិទ្ធិរបស់ជនរងគ្រោះ

ក្រៅពីសិទ្ធិដែលបានលើកឡើងខាងលើ ជនរងគ្រោះនៅមានសិទ្ធិផ្សេងទៀត ដូចជា សិទ្ធិមានមេធាវី សិទ្ធិធ្វើជាសាក្សី ឬសិទ្ធិចូលរួមក្នុងការបើកសវនាការជំនុំជម្រះជាសាធារណៈ ជាដើម។

ជាងនេះទៅទៀត ច្បាប់ស្តីពីអង្គជំនុំជម្រះវិសាមញ្ញ មាត្រា ៣៣ ចែងថា អង្គជំនុំជម្រះវិសាមញ្ញត្រូវ *“ផ្តល់នូវការការពារជូនជនរងគ្រោះ”* ដោយរាប់បញ្ចូលទាំងសិទ្ធិ ការពារដល់អត្តសញ្ញាណរបស់ជនរងគ្រោះផងដែរ។ ប៉ុន្តែ ច្បាប់នេះមិនបានបញ្ជាក់លំអិតនោះទេ។



# សាក្សី

សាក្សីគឺ ជាជនណាម្នាក់ដែលមានព័ត៌មាន ឬភស្តុតាងទាក់ទងនឹងជនល្មើស ។

## ក- សាក្សីមានប្រភេទខុសគ្នាគឺ

- *សាក្សីឃើញដោយផ្ទាល់ភ្នែក* : គឺជាមនុស្សណាម្នាក់ដែលឃើញអ្វីមួយដោយផ្ទាល់នឹងភ្នែក និង ឮដោយផ្ទាល់ត្រចៀករបស់ពួកគេ ។
- *សាក្សីជាជនរងគ្រោះ* : គឺជាជនរងគ្រោះ ដែលមិនបានសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចូលក្នុងសវនាការដើម្បីបំភ្លឺតុលាការ ។

## ខ- សិទ្ធិជាមូលដ្ឋានរបស់សាក្សី ដែលផ្តល់ឱ្យដោយច្បាប់ប្រទេសកម្ពុជាមានដូចជា :

- ការចូលរួមផ្តល់នូវសក្ខីភាពរបស់ខ្លួននៅក្នុងសវនាការជំនុំជម្រះជាសាធារណៈ ឬ ជាសម្ងាត់ (សិទ្ធិស្ថិតក្នុងភាពអនាមិកៈ សិទ្ធិមិនបញ្ចេញឈ្មោះ ឬ អត្តសញ្ញាណរបស់ខ្លួន )
- សាក្សីមិនត្រូវបានគំរាមកំហែង សំឡុត ឬកៀបសង្កត់អោយឆ្លើយដាច់ខាត (រាល់ការបង្ខិតបង្ខំសាក្សីត្រូវទទួលទោស ជាប់ពន្ធនាគារពី ១ឆ្នាំ ទៅ ២ឆ្នាំ មាត្រា ៥៥ នៃច្បាប់អ៊ុនតាក់ )
- សាក្សីដែលមកបង្ហាញខ្លួន តាមដីកា ឬការស្នើសុំរបស់ចៅក្រម សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា

នឹងមិនត្រូវចោទប្រកាន់ ឃុំខ្លួន ឬជាកម្មវត្ថុនៃការរឹតត្បិតណាមួយផ្សេងទៀត លើសេរីភាពរបស់ពួកគេដោយអាជ្ញាធរកម្ពុជាឡើយ ។ (មាត្រា ២២ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ) ។

### គ- តួនាទីរបស់សាក្សី

ក្រៅពីសិទ្ធិរបស់ពួកគេ សាក្សីត្រូវធ្វើការស្បថថានិយាយការពិត នឹងមិនត្រូវភូតកុហកចៅក្រមឡើយ (មាត្រា ៥៦នៃច្បាប់អ៊ិនតាក់)។

សហចៅក្រម ឬ សហព្រះរាជអាជ្ញា មានអំណាចក្នុងការសួរសាក្សី (មាត្រា២៣នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញ) ។

ជនដែលត្រូវកោះហៅឱ្យធ្វើជាសាក្សីដោយចៅក្រមស៊ើបអង្កេតត្រូវតែឆ្លើយតបទៅនឹងការកោះនោះ (មាត្រា៨៤ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌរដ្ឋកម្ពុជា)។

### ឃ- ការការពារសាក្សី

ការការពារសាក្សី គឺគ្រាន់តែចែងឡើងតាមភាគខ្លះៗដោយច្បាប់កម្ពុជាតែប៉ុណ្ណោះ ដោយពុំបានចែងលំអិតនោះទេ។

បញ្ញត្តិអន្តរជាតិផ្ដល់លទ្ធភាពដល់តុលាការធ្វើការចាត់វិធានការណាមួយ ដើម្បីធានាឱ្យមាន សមត្ថភាពសុខុមាលភាពទាំងផ្លូវកាយ ទាំងផ្លូវចិត្ត មានសេចក្ដីថ្លៃថ្នូរ និងការគោរពដល់សិទ្ធិឯកជនរបស់សាក្សី។



## ជនជាប់ចោទ

ជនជាប់ចោទ គឺជាជនសង្ស័យ ដែលព្រះរាជអាជ្ញាជឿថា ខ្លួនមានភស្ដុតាងគ្រប់គ្រាន់អាច បញ្ជាក់ថាពិតជាជនដែលបានប្រព្រឹត្តបទល្មើសណាមួយ និងបានសំរេចធ្វើការចោទប្រកាន់ជាផ្លូវការទៅតុលាការហើយ ។

## ការងាររបស់អ្នកឃ្លាំមើល



- ផ្ដល់ព័ត៌មានលំអិតអំពីការស៊ើប អង្កេត និងដំណើរការក្ដីដល់ជនរងគ្រោះ និងសាក្សីសំខាន់ៗ ។
- តាមជនរងគ្រោះ ឬសាក្សី ទៅគ្រប់ដំណាក់កាលដោះស្រាយរឿងក្ដីរបស់តុលាការ ។
- ជួយសង្គ្រោះជនរងគ្រោះ និងសាក្សីដែលមានអារម្មណ៍ភ័យខ្លាច ឬបានទទួលការគំរាមកំហែង ។
- ធានាឱ្យមានផាសុកភាពដល់សាក្សីនៅពេលគេកំពុងរង់ចាំធ្វើជាសាក្សី ។
- ផ្ដល់ការគាំទ្រផ្លូវចិត្តដល់ជនរងគ្រោះ និងសាក្សី ។
- ជំរុញឱ្យមានសេចក្ដីក្លាហានក្នុងការផ្ដល់សក្ខីភាពអំពីបទពិសោធន៍នៃការឈឺចាប់ពីអតីតកាល ។
- ការសំងាត់ត្រូវបានធានា ។
- រក្សាការទំនាក់ទំនងជាមួយសាក្សីបន្ទាប់ពីដំណើរការ កាត់ក្ដី ។
- រាយការណ៍រាល់ការរំលោភ សិទ្ធិជនរងគ្រោះ និងសាក្សី នេះជាការឃ្លាំមើលយ៉ាង សកម្មមួយ ។

## យល់ដឹងអំពី

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬ សាលាក្ដីកាត់ទោសមេដឹកនាំខ្មែរក្រហម

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ១៩៧៩

ផលិតដោយ

សមាគមអាដហុក
ADHOC

ឧបត្ថម្ភដោយ

Ambassade van het
Koninkrijk der Nederlanden

អាសយដ្ឋាន

ផ្ទះលេខ ៣ ផ្លូវ១៥៨ ឬឧកញ៉ាត្រឿងកាង សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ប្រទេសកម្ពុជា ទូរស័ព្ទលេខ : (៨៥៥-២៣) ២១៨ ៦៥៣ / ៩៨២ ៤០៧
ទូរសារលេខ : (៨៥៥-២៣) ២១៧ ២២៩
Email: adhoc@forum.org.kh, www.adhoc-chra.org